# លក្ខខណ្ឌ និង ដំណើរការស្នើសុំអាហាររូបករណ៍

## គោលបំណង

ដើម្បីផ្តល់អាហារូបករណ៍និងជំនួយជាអាហារូបករណ៍ដល់និស្សិតដែលមានតម្រូវការផ្នែកហិរញ្ញវត្ថុ អោយបានចូលរៀននៅតាមសាលារដ្ឋ / ឯកជន (ទាំងថ្នាក់បឋមសិក្សា,អនុវិទ្យាល័យ ,វិទ្យាល័យ, សាកលវិទ្យាល័យ, និងថ្នាក់ក្រោយបញ្ចប់ការសិក្សា)។

## លក្ខខណ្ឌនៃការដាក់ពាក្យ:

**១**. សម្រាប់បេក្ខជនដែលមកដាក់ពាក្យអាហារូបករណ៍លើកដំបូងទាំងអស់ ត្រូវមានលិខិតបញ្ជាក់ជីវភាពពីមេភូមិ (ប័ណ្ណក្រីក្រ) និង និងលិខិតបញ្ជាក់ពីគ្រូគង្វាលដើម្បីបញ្ជាក់ពីតម្រូវការ ឬការខ្វះខាតផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។

**ក**. ចំពោះនិស្សិតដែលកំពុងតែទទួលបាននូវអាហារូករណ៍ សូមភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ជីវភាពពីមេភូមិ និង លិខិតបញ្ជាក់ពីគ្រូគង្វាល ឬពីអ្នកដែលណែនាំមក នៅពេលដែលពួកគេបញ្ចប់ ការសិក្សាពីមួយ កម្រិតទៅមួយ កម្រិតទៀត (ពីថ្នាក់បឋមទៅអនុវិទ្យាល័យ/ពីអនុវិទ្យាល័យទៅវិទ្យាល័យ/ ពីវិទ្យាល័យទៅមហាវិទ្យាល័យ)

**២**. សម្រាប់និស្សិតសាកលវិទ្យាល័យ ត្រូវចូលរួមជាបដិភាគចំនួន ៥០ ដុល្លា ក្នុងមួយឆមាស (យ៉ាងតិច) ទៅលើការបង់ថ្លៃសិក្សា (អាស្រ័យទៅលើថ្លៃសិក្សាផងដែរ)

**៣**. សម្រាប់សិស្ស/និស្សិតដែលទទួលបានអាហាររូបករណ៍ទាំងអស់ តម្រូវអោយនាំយកនូវព្រិត្តិបត្រពិន្ទុប្រចាំឆ្នាំនីមួយៗ ឬ ឆមាសនីមួយៗដែលបានជាប់គ្រប់មុខវិជ្ជា ឬ ឡើងថ្នាក់ ដើម្បីមកបន្តទទួលនូវអាហាររូបករណ៍សម្រាប់ឆ្នាំសិក្សាបន្ទាប់។

**ក**. ក្នុងករណីដែលសិស្សដែលមិនទទួលបាននូវពិន្ទុល្អ (ធ្លាក់) ពួកគេនឹង ទទួលបាននូវលិខិតព្យួរអាហារូបករណ៍ជាបណ្តោះអាសន្ន។ ប្រសិនបើពួកគេនៅតែមានពិន្ទុធ្លាក់ទៀតសិស្ស នឹងត្រូវបញ្ឈប់ពីកម្មវិធីផ្តល់អាហារូបករណ៍របស់យើងតទៅ។

**ខ**. ប្រសិនបើនិស្សិតប្រលងធ្លាក់នូវមុខវិជ្ជាណាមួយ និស្សិតត្រូវចូលរួមបដិភាគបន្ថែម ៥០ ដុល្លាពីលើបដិភាគដែលគាត់ត្រូវបង់ជារៀងរាល់ឆមាស និងបើសិនជាក្នុងករណីដែលនិស្សិតប្រលង ធ្លាក់លើមុខវិជ្ជាឯកទេស និស្សិតត្រូវចូលរួមបដិភាគ ១០០ ដុល្លាបន្ថែមពីលើបដិភាគដែលគាត់ត្រូវបង់ប្រចាំឆមាស។

**ឧទាហរណ៍ ៖ សម្រាប់និស្សិតដែលបង់ត្រូវបង់ ២៥០ ដុល្លា/ឆមាស**

- ប្រសិនបើនិស្សិតរៀនមុខវិជ្ជា គណនេយ្យ ហើយក្នុង ឆមាសទី ១ ឆ្នាំទី ១ គាត់ត្រូវរៀន ៥ មុខវិជ្ជា។ ហើយនៅចុងឆមាសទី ១ និស្សិតប្រលងធ្លាក់ ២ មុខវិជ្ជា (មិនមែនជាមុខវិជ្ជាឯកទេស) ដូច្នេះសម្រាប់ឆមាសទី ២ និស្សិតត្រូវបង់ថ្លៃសិក្សាចំនួន ១០០ ដុល្លា ហើយ អង្គការ GBGM នឹងបង់តែ ១៥០ ដុល្លាប៉ុណ្ណោះ។
- ប្រសិនបើនិស្សិតរៀនមុខវិជ្ជា គណនេយ្យ ហើយក្នុង ឆមាសទី ១ ឆ្នាំទី ១ គាត់ត្រូវរៀន ៥ មុខវិជ្ជា។ ហើយនៅចុងឆមាសទី ១ និស្សិតប្រលងធ្លាក់ ២ មុខវិជ្ជា។ ហើយក្នុង ២ មុខវិជ្ជានោះ មាន ១ មុខជាមុខវិជ្ជាឯសទេស (មូលដ្ឋានគ្រឹះគណនេយ្យ) ដូច្នេះសម្រាប់ឆមាសទី ២ និស្សិតត្រូវបង់ថ្លៃសិក្សាចំនួន ១៥០ ដុល្លា ហើយអង្គការ GBGM នឹងបង់តែ ១០០ ដុល្លា ប៉ុណ្ណោះ។

៤. សិស្ស/និស្សិតត្រូវទទួលខុសត្រូវក្នុងការបង់សងត្រលប់មកវិញនូវថ្លៃសិក្សាដែលអង្គការ GBGM បានចំណាយសម្រាប់ការសិក្សារបស់អ្នក នៅពេលណាដែលអ្នកឈប់រៀន (មិនបានបញ្ចប់ការសិក្សា ឬ ឈប់ពាក់កណ្ដាលទី)។

៥. សម្រាប់សិស្សដែលបញ្ចប់ការសិក្សាតាមកម្រិតនីមួយៗ ពីកម្រិតបឋម ទៅអនុវិទ្យាល័យ ពីអនុវិទ្យាល័យទៅវិទ្យាល័យ ពីវិទ្យាល័យទៅមហាវិទ្យាល័យ ពួកគេត្រូវសរសេរសំណេរពីគោលបំណងដែលគេចង់ធ្វើនៅពេលអនាគតនឹងយកមក ប្រគល់ជូនដល់គណកម្មការអាហារូបករណ៍ (មិនមែនចម្លងពីសំណេរចាស់)។

៦. សម្រាប់និស្សិតដែលទើបតែចូលរៀននៅមហាវិទ្យាល័យ ពួកគេត្រូវតែប្រលងជាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ និងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របណ្ដោះអាសន្នមកជាមួយនឹងពាក្យស្នើសុំអាហារូបករណ៍

៧. មិនអាចមានសមាជិកលើសពី ម្នាក់ (០១ នាក់) នៅក្នុងគ្រួសារតែមួយអាចដាក់ពាក្យស្នើសុំអាហារូបករណ៍បាន

## ដំណើរការនៃការផ្ដល់អាហារូបករណ៍

- បេក្ខជនដែលដាក់ពាក្យស្នើសុំអាហារូបករណ៍ទាំងអស់ត្រូវបំពេញពាក្យសុំអាហារូបករណ៍ និង ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលបានបញ្ជាក់ខាងលើ
- បេក្ខជនដែលដាក់ពាក្យស្នើសុំអាហារូបករណ៍សម្រាប់ថ្នាក់មហាវិទ្យាល័យទាំងអស់ត្រូវឆ្លងកាត់ការសម្ភាសពីគណកម្មាការផ្ដល់អាហារូបករណ៍ជាមុនសិន
- គណកម្មាការផ្ដល់អាហារូបករណ៍នឹងជូនដំណឹងត្រឡប់ទៅបេក្ខជនដែលបានដាក់ពាក្យស្នើសុំអាហារូបករណ៍វិញបន្ទាប់ពីការត្រួតពិនិត្យនូវពាក្យស្នើសុំអាហារូបករណ៍ (និងការសម្ភាសរួចរាល់)

## កាលបរិច្ឆេទនៃការដាក់ពាក្យ

- សម្រាប់សិស្ស ឬ និស្សិត ដែលដាក់ពាក្យស្នើសុំអាហាររូបករណ៍ជាលើកដំបូងសូមបំពេញពាក្យស្នើសុំអាហារូបករណ៍សម្រាប់ឆ្នាំសិក្សានីមួយៗ សូមដាក់ពាក្យមកកាន់ការិយាល័យ យូ អឹម ស៊ី UMC ចាប់ពីថ្ងៃទី កក្កដា ដល់ ខែ ធ្នូ។